# សិលាចារឹកប្រាសាទចារ K.២៨៧ មេទ្វារខាងត្បូង

## ១- ព័ត៌មានទូទៅ

ប្រាសាទចារ មានទីតាំងស្ថិតនៅភូមិប្រាសាទចារ្យ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។ ប្រាសាទនេះកសាងឡើងនៅរវាងចុងស.វ.ទី១០ មានខឿនជាថ្នាក់ៗ និងមានប្រាង្គប្រាង្គចំនួនបី។ នៅប្រាសាទនេះ មានសិលាចារឹកចំនួនពីរផ្ទាំងជាភាសាខ្មែរ ចុះលេខសម្គាល់ K.២៨៧ ចារលើមេទ្វារខាងត្បូងចំនួន៤៥បន្ទាត់ និងនៅមេទ្វារខាងជើងចំនួន៣៩បន្ទាត់។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញតែសិលាចារឹកនៅមេទ្វារខាងត្បូងប៉ុណ្ណោះ។

ខាងក្រោមនេះជាអត្ថន័យសំខាន់ៗរបស់សិលាចារឹកៈ

១- នាមហាសករាជឆ្នាំ៩០១ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៧៩ ថ្ងៃអាទិត្យ ទី៥ កើត ខែជេស្ឋ មានព្រះរាជបញ្ជារបស់ព្រះបាទស្រីជ័យវរ្ម័ទេវទី៥ បានត្រាស់ដល់កំស្តេងព្រះគ្រូ និងមន្ត្រីសែស្រឡាយរាជវង្ស៣នាក់ គឺកំស្តេងស្រីវីរេន្ទ្រវរ្ម័ កំស្តេងវីរេន្ទ្រាធិបតីវរ្ម័ កំស្តេងស្រីមហីធរវរ្ម័ ឱ្យទៅប្រទានដីនៅឯស្ទឹងដល់មន្ត្រី៤នាក់ ដើម្បីចាត់ចែងបង្កើតជាស្រុក តម្កល់ព្រះ និងឱ្យក្រុមគ្រួសារអ្នកទាំងនោះរស់នៅ។

២- ព្រះដែលតម្កល់មានដូចជា ព្រះសិវលិង្គ ព្រះបរមេស្វរ ព្រះភគវតីចំនួន ២ ដាក់អាស្រ័យផលរួមជាមួយនឹងប្រាសាទព្រះកម្តែងជគតស្រីកទ្រេស្វរ ក្នុងសហគមន៍ប្រាសាទលិង្គបុរ ត្រូវនឹងតំបន់កោះកេរសព្វថ្ងៃ។ ចំណែកឯប្រាសាទព្រះនារាយណ៍ ត្រូវដាក់រួមអាស្រ័យផលជាមួយប្រាសាទព្រះកម្តែងអញស្រីចាម្បេស្វរ។ រូបប្រតិមាព្រះដែលសាងតម្កល់នោះ មានព្រះបរមេស្វរ(ឥស្វរ) និងព្រះភគវតី(ឧមា) ឆ្លាក់ក្នុងទម្រង់រូបរាងមុខមាត់របស់មនុស្ស គឺព្រះបរមេស្វរ មានមុខមាត់ជាកំស្តេងស្រីរាជបតីវរ្ម័ ព្រះភគវតី១មានមុខមាត់ជាតាញកម្តែងអញ ព្រះភគវតីមួយទៀតមានមុខមាត់ជាតេងដូន ដែលជាជីដូនរបស់កំស្តេងអញស្រីនរបតីវីរវរ្ម័ និងម្រតាញខ្លោញស្រីជយាយុធវរ្ម័។ អ្នកទាំងនោះ សុទ្ធតែជាអ្នកជាប់សែស្រឡាយ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

រាជវង្សៗ ទំនៀមបែបនេះ យើងសង្កេតឃើញមានតាំងពីបុរាណ រហូតមកដល់សម័យទំនើប ដូចជាព្រះបាទនរោត្តមត្រាស់បង្គាប់ឱ្យសាងព្រះពុទ្ធស្រីអារ្យមេត្រីមួយអង្គ យកលំនាំតាមកម្ពស់កម្ពស់របស់ទ្រង់ៗ ដូចគ្នាដែរ គំនូរនៅតាមវត្តមួយចំនួនក៏មានគូរគំនូរព្រះបាទបរមរតនៈកោដ្ឋ នៅក្នុងសាច់រឿងពុទ្ធប្រវត្តិផងដែរៗ នេះជារបៀបមួយ ដែលភ្ជាប់ខ្លួនមនុស្សទៅនឹងទេពៗ

៣- សេចក្តីចុងក្រោយ គឺជាការកំណត់ពីព្រំដីដែលត្រូវថ្វាយទៅប្រាសាទទាំងនោះ ដោយមានបញ្ជាក់អំពីប្រភពដែលទទួលបានដីនោះ ដូចជាបានមកដោយព្រះរាជប្រទាន ការដោះដូរ និងការជាវជាដើមៗ

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

(១) //๏//៩០១គកបញ្ចមីកេតិជេ្យស្ថតោយចន្ទ្រមាសវៃគាខ◌ោ------ (២) អាទិត្យវារបុប្បនក្សត្រនុមានិវ្រះគាសនធូលីជេង៑វ្រះកម្រ[[តេង៑]] (៣) អញ៑ស្រីជយវម៌្មទេវតស្តេង៑អញ៑វ្រះគុរុកំស្តេង៑ស្រីវីរេន្ទ្រវម៌្មកំស្តេង៑ស្រី[[វីរេ]] (៤) ន្ទ្រាធិបតិវម៌្មកំស្តេង៑ស្រីមហីធរវម៌្មប្រេទៅឱយិវ្រះករុណាប្រសាទភូមិអាយិ (៥) ថ្មីង៑តតាញ៑កម្រតេង៑អញ៑អាយិអាយិតកំស្តេង៑ស្រីរាជបតិវម៌្មតកំស្តេង៑ស្រីនរ (៦) បតិវីរវម៌្មតម្រតាញ៑ខ្លោញ៑ស្រីជយាយុធវម៌្មបិចតិស្រុកិទុកិវ្រះបិឱយិតកុលេត (៧) ស្ត្រីជនផោង៑អង្គយ្ឋគី·វ្រះកម្រតេង៑អញ៑គិរលិង្គ·វ្រះកម្រតេង៑អញ៑បរមេគ្វរ (៨) រូបកំស្តេង៑ស្រីរាជបតិវម៌្ម·វ្រះកម្រតេង៑អញ៑ភគវតីរូបតាញ៑កម្រតេង៑អញ៑ (៩) វ្រះកម្រតេង៑អញ៑ភគវតីរូបតេង៑ត្វនិតយាកំស្តេង៑ស្រីនរបតិវីរវម៌្មម្រតាញ៑ (១០) ខ្លោញ៑ស្រីជយាយុធវម៌្ម·សំគណានុកម្រតេង៑ជគតិស្រីភទ្រេគ្វរអន្ទ្រាយិលិង្គបុរ (១១) វ្រះកម្រតេង៑អញ៑នារាយនសំគណានុវ្រះកម្រតេង៑អញ៑ស្រីចម្បេគ្វរ//๏ (១២) ចង្វាត្តភូមិនេះតោយិបូវ៌្វអង្វេធ្ធិង៑ភូមិត្រវាង៑វៀង៑តតីម្រតាញ៑ត្រីខ្សាចិ(វ្កុកិ) (១៣) ឱយ្តកំស្តេង៑ស្រីរាជបតិវម៌្ម·តោយិអគ្នេយប្រសប្តគិភូមិគុហេតតិវាបិហា-- (១៤) អាប្តក្ធ្ចត្យនាឯកខ្សុអ្នកិបង្គំប្យង៑និវេទនបិឱយ្តកំស្តេង៑ស្រីរាជបតិវម៌្ម·តោយិទក្សិណ (១៥) ប្រសប្តគិចំនតិស្តេញ៑ឆោកិថ្មោ·តោយិនៃរ្ឫតីយប្រសបិត្រវាង៑ខ្ពសិតោយិបគ្ចិមប្រ (១៦) សបិគិវង្សាន·តោយិវាយវ្យត្រវាង៑វេង៑ប្រសបិនុរាមក្សេត្រ·តោយឧត្តរនុតគានប្រ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

*សបិ (១៧) ភូមិកំស្តេងឝ្រីវីរេន្ទ្រវម៌្ម•ភូមិនាវាបិរិសិភាគវតអង្គួយកំនុងចង្វាតនេះ[[កំស្តេងឝ្រី]] (១៨) [[ឝ្រីរាជបតិ]]វម៌្មបង្គំថ្បូងនិវេទនសុំភូមិម្ហូតកជនអាយ៉--តិបិឱយ៉ថ្ងរតវាបិរិសិ[[ន្នុ]] (១៩) ភូមិស្តលាប្រវចតីកំស្តេងឝ្រីនរបតិវីរវម៌្មទុញ៊ែនុវ៉ោទីបទិគះមាសិប្រាកក្របីតវាបិ[អ្យត] (២០) ទគាជិក្ចូតឆ្នាំវ្រះក្រលាផ្ទំឆោកិគ្រគ្យរ៍•ភូមិភាគអន្ទេម្វាយតោយបគ្ចិមតិកំស្តេងឝ្រីរា (២១) ជបតិវម៌្មទុញ៊ែនុវ៉ោទីបទិគះថ្នបិចន្ទ្យាកតវាបិស្វស្តិអ្នកិវ្រះធ្លារ៍•ភូមិត្រវាងខ្ពស-(២២) កំស្តេងឝ្រីរាជបតិវម៌្មជោរិនុវ៉ោទិបទិគះថ្នបិចន្ទ្យាកក្របីតឃោសំរាចិអ្នកិវ្រះត្រវាង-(២៣) ស្រុកតែំតន្នោតិអាយ៉ិកន្តាលិទន្វេនុខ្ញុំផ្វេគិតិម្រតាញឝ្រីគុណបណ្ឌិតឱយ្តកំស្តេងឝ្រី (២៤) រាជបតិវម៌្មមន្ទានិវ្រះគាសនប្រេស្តាបនារូបកំស្តេងឝ្រីរាជបតិវម៌្មតិឱយ៉បំរេតរូបកំស្តេង (២៥) ភូមិតំបុងតិវ្រះករុណាប្រសាទ•ភូមិតំបុងភាគម្វាយតិទុកិថ្បលិនុខ្ញុំផ្វេគិនាំវ្រះបយ៉្យ (២៦) ងទៅលិង្គបុរ•ភូមិតំបុងភាគម្វាយ៉ិស្តេងអញ៊វ្រះគុរុឱយ្តកំស្តេងឝ្រីនរបតិវីរវម៌្មស្ថាប (២៧) នាវ្រះគិវលិង្គតគិសំគណានុលិង្គបុរសោត•ភាគម្វាយអាយ៉ិល្ពុកិឱយ៉ចំនាំរង្កោលិះវ្យរតវ្រះ (២៨) ព្រាហ្មណគាល•ភាគម្វាយអាយ៉ិវ្នុរវ្យាំងឱយ៉ិទៅបំរេតវ្រះហេមគ្ហង្គគិរិ•ភាគម្វាយ៉ិរសោង (២៩) ទៅតវ្រះកម្រតេងអញ៊ិកគវតីរូបតេងត្វនិតយាកំស្តេងឝ្រីនរបតិវីរវម៌្ម•ភូមិគ (៣០) ម្រ្យាងតិទុញ៊ិតមុច្តិយុធស្ថាបនាភគវតីមហិបាសុរអាសនកន្ទោងកម្រតេងអញ៊ិអា (៣១) យអង្វេទន្វេតគិ//ភូមិតែំស្វាម្ហូតកជនតិស្តេងអញ៊វ្រះគុរុបង្គំថ្បូងនិវេទនឱយ៉ (៣២) វ្រះករុណាប្រសាទស្ថាបនាគិវលិង្គតគិសំគណានុកម្រតេងជគតលិង្គបុរសោត// (៣៣) ភូមិចន្ទត្តែតិម្រតេញហ្ឫទយភារឆ្នាំវ្រះក្រលាផ្ទំនាត្រីណិសំលាបិតម្រ្យសារនៃ (៣៤) កំស្តេងវ្យរហេតុច្យស្រូវមនិអ្យត្តម្រ្យនុសោងតម្រ្យកំស្តេងឱយ៉ិភូមិចន្ទត្តែស្ថាបនា (៣៥) គិវលិង្គតគិសំគណានុលិង្គបុរសោត//ភូមិលិំស្តុត្តិវាបិដ្វាទឆ្នាំវ្រះក្រលាផ្ទំនាទោឱ (៣៦) យ្តកំស្តេង•ភូមិស្នាំថ្កុះតិកំស្តេងឝ្រីរាជបតិវម៌្មទុញ៊ិតវាបិទាវគ្គ៌ជ្រុវបុរនុវ៉ោទិបទិ (៣៧) គះចន្ទ្យាកក្របីស្ថាបនាវ្រះវិឃ្នេគតគិឱយ៉ក្រិយាអាយ៉ិធ្ទិង//ភូមិល្ង៉ោតីកំស្តេងទុញ៊ិត (៣៨) វាបិគោកន្ទ្យងបំរេនុប្រាក្កនុចន្ទ្យាក្កបិចតិស្រុកិទុកិខ្ញុំឱយ្តវ្រះកម្រតេងអញ៊ិកគវតិរូបតា (៣៩) ញ៊ិកម្រតេងអញ៊ិ//ភូមិច្យត្រាងប្រមានមល្យាងតិកំស្តេងឝ្រីនរបតិវីរវម៌្មសុំវ្រះករុណា (៤០) ប្រសាទបិចតិស្រុកិទុកិខ្ញុំ*

*អត្ថបទដោយៈ ហ៊ិន ឈុនតេង*

តគិឱយ្តិវ្រះកម្រតេងអញិភគវតីរូបតេងត្វនិតយាកំស្តេងគ្រីនរ (៤១) បតិវីរវម៌្ម//ស្រុកិរត្នបវ៌ តប្រមានិភីមបុរតិតេងមាតអ្នកិខ្ញោញិកំស្តេងគ្រីរាជបតិវម៌្មជូន្ត (៤២) វ្រះកំម្រតេងអញិបរ មេគ្វរតូរូបកំស្តេងគ្រីរាជបតិវម៌្មជូនិខ្ញុំសវាលវ្ទ្វគតម្វាយប្រវ្យល (៤៣) ភូមិស្តលាប្រវច សោតិតិម្រតាញិខ្ញោញគ្រីជយាយុធវម៌្មទុញិនុគ្រលោង្តែម្វាយខាលិ (៤៤) ប្រាកិម្វាយងនិ ជ្យងម្វាយជួយៅម្វាយថ្នបិយៅម្វាយតវាបិអ្សតិទគាជីក្ទ្វតថ្នាំវ្រះក្រលាផ្ទុំ (៤៥) ធោកិគ្រគ្យរិ បិឱយ្តវ្រះកម្រតេងអញិភគវតិរូបតេងត្វន្តយាម្រតាញិខ្ញោញិ //

## ៣- អត្ថបទប្រែសម្រួល

(១-៧) នាមហាសករាជឆ្នាំ ៩០១ ទី៥កើត ខែជេស្ឋ តាមខែចន្ទគតិ ខែពិសាខ---- ថ្ងៃអាទិត្យ នក្សត្របុស្ស នូវមានព្រះរាជសាសន៍ធូលីជើងព្រះកម្ដែងអញស្រីជ័យវម៌្មទេវ(ទី៥) ដល់ស្ដេងអញព្រះគ្រូ កំស្ដែងស្រីវីរេន្ទ្រវម៌្ម កំស្ដែងវីរេន្ទ្រាធិបតីវម៌្ម កំស្ដែងស្រីមហីធរវម៌្ម ត្រាស់ប្រើទៅឱ្យព្រះរាជប្រទានដីនៅឯត្នឹងដល់តាញកម្ដែងអញនៅឯអ្វាយ ដល់កំស្ដែងស្រីរាជបតីវម៌្ម ដល់កំស្ដែងនរបតីវីរវម៌្ម ដល់ម្រតាញខ្ញោញស្រីជយាយុធវម៌្ម ដើម្បីចាត់ស្រុក តម្កល់ព្រះ គប្បីឱ្យដល់ក្រុមគ្រួសារជាស្ត្រីផោង រស់នៅទីនោះ។

(៧-១១) ព្រះកម្ដែងអញសិវលិង្គ ព្រះកម្ដែងអញបរមេសូរ(មាន)រូបកំស្ដែងស្រីរាជបតីវម៌្ម(ជាតំណាង) ព្រះកម្ដែងអញភគវតី(មាន)រូបតាញកម្ដែងអញ(ជាតំណាង) ព្រះកម្ដែងអញភគវតី(មាន)រូបតេងជូន ដែលជីយាយកំស្ដែងអញស្រីនរបតីវីរវម៌្ម(និង)ម្រតាញខ្ញោញស្រីជយាយុធវម៌្ម (ដាក់)រួមក្រុមជាមួយកម្ដែងជគតស្រីភទ្រេសូរ (ក្នុង)អទ្រោយលិង្គបុរ។ (ឯ)ព្រះកម្ដែងអញនារាយណ៍ (ដាក់)រួមក្រុមជាមួយព្រះកម្ដែងអញស្រីចម្បេសូរ។

(១២-១៧) នេះគឺព្រំដី។ ទៅកើតដល់ត្រង់ស្ទឹងបត់ ដីត្រពាំងញោង ដែលម្រតាញត្រីខ្សាច់ភ្ជុកឱ្យដល់កំស្ដែងរាជបតីវម៌្ម។ ទៅអាគ្នេយ៍ប្រសប់នឹងដីគុហេ ដែលវាបបហា---អ្នកបម្រើជំនិតថ្នាក់ឯក ខ្ទីយកទៅក្រាបថ្វាយបង្គំទូលថ្វាយសុំឱ្យដល់កំស្ដែងស្រីរាជបតីវម៌្ម។ ទៅត្បូងប្រសប់នឹងចំណាតស្ដែងធកថ្ម។ ទៅនិរតីប្រសប់ត្រពាំងខ្ពស់។ ទៅលិចប្រសប់សិវ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ផ្ទាន។ ទៅពាយ័ព្យត្រពាំងវែងប្រសប់និងរាមក្សេត្រ។ ទៅជើងនិងវៀសានប្រសប់ដីកំស្តែង ស្រីវីរេន្ទ្រវម្ម៌។

(១៧-២៥) ដីវាបវិសជាកគវ័តដែលរស់នៅក្នុងព្រំដីនេះ។ កំស្តែងស្រីរាជបតិវម្ម៌ក្រាបបង្គំទូលថ្វាយសុំដីជាទ្រព្យមរតកនៅឯ--តី ដើម្បីឱ្យជាផ្ទូរដល់វាបវិស (ជាមួយ)ដីស្ដលាប្រវច(ដែល)កំស្តែងស្រីនរបតីវីរវម្ម៌ទិញដោយថ្ងៃរវៅទី កន្ទោរស្ពោះ មាស ប្រាក់ ក្របី ពីវាបអ្សត ទសាធិក្រឹត ជាឆ្នាំក្រលាផ្ចុំ (នៅ)ធោកគតីរ។ ដី១អន្ទើ ទៅលិច កំស្តែងស្រីរាជបតិវម្ម៌ទិញដោយថ្ងៃរវៅទិ កន្ទោរស្ពោះ សំពត់ដណ្ដាប់ សម្បៀក ពីវាបស្ទួស្ដីជាអ្នកព្រះច្បារ។ ដីត្រពាំងខ្ពស់ កំស្តែងស្រីរាជបតីវម្ម៌ ដាវដោយថ្ងៃរវៅទិ កន្ទោរស្ពោះ សំពត់ដណ្ដាប់ សម្បៀក ក្របី ពីឃោសំរាច ជាអ្នកព្រះត្រពាំង។ ភូមិដើមត្នោតនៅកណ្ដាលទន្ទេ និងអ្នកបម្រើការគឺម្រតាញស្រីគុណបណ្ឌិតឱ្យដល់កំស្តែងស្រីរាជបតីវម្ម៌។ មានព្រះរាជសាសន៍ ស្ដេចត្រាស់ប្រើស្ថាបនារូបកំស្តែងស្រីរាជបតីវម្ម៌ និងឱ្យអ្នកបម្រើរូបកំស្តែង ព្រមទាំងដីតំបុង ជាព្រះរាជប្រទាន។ ភូមិតំបុងមួយភាគ ទុកសម្រាប់ហ្វូងចិញ្ចឹមសត្វ និងអ្នកបម្រើការ គឺសម្រាប់នាំព្រះប្រេងទៅលិង្គបុរ។ ភូមិតំបុងមួយភាគទៀត ស្តែងអញព្រះគ្រូឱ្យដល់កំស្តែងស្រីនរបតីវីរវម្ម៌(សម្រាប់)ស្ថាបនាព្រះសិវលិង្គ និងដាក់រួមក្រុមជាមួយលិង្គបុរផង។ ដីមួយភាគទៀតនៅឯល្ពោក ឱ្យគ្រឿងរណ្ដាប់រៀបចំបូជាមានអង្ករ២លិះដល់ព្រះព្រាហ្មណ៍សាល។ ដីមួយភាគឯផ្ទូររវៀង ឱ្យទៅអ្នកបម្រើព្រះហោមស្រឹង្គគិរី។ មួយភាគ សងទៅព្រះគម្តែងអញភគវតី(មាន)រូប(តំណាងជា)តេងដូនជាយាយរបស់កំស្តែងស្រីនរបតីវីរវម្ម៌។ ដីគម្រៀង ទិញពីអ្នកប្រដាល់ (សម្រាប់)ស្ថាបនាព្រះភគវតីមហិង្សាសុរជាអាស្នាព្រះនាងជាគម្តែងអញនៅឯជ្រុងបារាយណ៍។ ដីដើមស្វាជាទ្រព្យមរតក ស្តែងញព្រះគ្រូក្រាបបង្គំទូលថ្វាយសុំជាព្រះរាជទានរបស់ព្រះករុណា ដើម្បីស្ថាបនាសិវលិង្គ រួមជាក្រុមជាមួយគម្តែងជគតលិង្គបុរដែរ។ ដីនៅចន្ទាត់ដៃ ម្រតេញហ្វូទ័យភាព ជាឆ្នាំព្រះក្រលាផ្ចុំថ្នាក់ត្រី (បាន)សម្ងាប់ដំរីសារបស់កំស្តែងចំនួន២ក្បាល ដោយហេតុ(វាមក)ស៊ីស្រូវ (ដ្បិត)ពុំមានដំរីសងដំរីរបស់កំស្តែងវិញ (ក៏)ឱ្យដីចន្ទាត់ដៃសម្រាប់ស្ថាបនាព្រះសិវលិង្គ ដើម្បីដាក់រួមក្រុមជាមួយលិង្គ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

បុរដែរ។ ដីរលំស្លុត វាបដ្វាទជាឆ្នាំព្រះក្រលាផ្ទុំថ្នាក់ទោ ឱ្យទៅកំស្តែង។ ភូមិស្នាំថ្កុះ កំស្តែងស្រីរាជបតីវម្ម័ ទិញពីវាបទា ជាក្រុមអ្នកច្រុវបុរ ដោយចូរៅទិ កន្ទោរស្តោះ សម្លៀង និងក្របី ដើម្បីស្ថាបនាព្រះគណេស(វិឃ្នេស) គឺឱ្យក្រយាបូជានៅឯស្ទឹង។ ដីរលោត កំស្តែងទិញពី វាបគោជាអ្នកក្មេងបម្រើដោយប្រាក់និងសម្លៀក ដើម្បីចាត់ស្រុក ទុកខ្ញុំបម្រើ ថ្វាយដល់ព្រះគម្តែងអញភគវតី(មាន)រូប(តំណាងជា)តាញគម្តែងអញ។ ដីច្បតក្រាំង នៅប្រមានមល្យាង កំស្តែងស្រីនរបតិវីរវម្ម័សុំព្រះករុណាព្រះរាជប្រទាន ដើម្បីចាត់ស្រុក ទុកខ្ញុំបម្រើ ថ្វាយព្រះគម្តែងអញភគវី (មាន)រូប(តំណាងជា)តេងដូនជាយាយកំស្តែងស្រីនរបតិវីរវម្ម័។ ស្រុករត្នបព៌ត នៅប្រមានភីមបុរ តេងមាជាករិយាកំស្តែងស្រីរាជបតីវម្ម័ថ្វាយដល់ព្រះគម្តែងអញបរមេស្វរ (មាន)រូប(តំណាង)ជាកំស្តែងស្រីរាជបតីវម្ម័ និងថ្វាយអ្នកបម្រើក្មេងចាស់ចំនួន១០៧នាក់។ ភូមិស្តលាប្រវចមួយទៀត ម្រតាញខ្ញោញស្រីជយាយុធវម្ម័ទិញដោយគ្រលោងដៃមួយ ខាលប្រាក់មួយទម្ងន់១ជញ្ជីង ជ្ង១យោ សំពត់ដណ្តប់១យោ ពីវាបអ្សត ជាទសាធិក្រឹត្យ និងជាឆ្នាំព្រះក្រលាផ្ទុំនៅធោកគគរី ដើម្បីថ្វាយដល់ព្រះគម្តែងអញភគវតី(មាន)រូប(តំណាងជា)តេងដូនជាយាយរបស់ម្រតាញខ្ញោញ។

## បញ្ជីឯកសារ

Cœdès, George. (1952). Inscriptions de Pràsàt Čàr. In Inscription *du Cambodge* (Vol. IV, pp. 140-150). Paris: Editions de Boccard.

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព




ផ្ទាំងថ្មចារឹកព័ត៌មានប្រាសាទចារ (រូបថត៖ រឿន សោម)



ប្រាសាទចារ (រូបថត៖ រឿន សោម)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ប្រាសាទចារ (រូបថត៖ រឿន សោម)



ប្រាសាទចារ (រូបថត៖ រឿន សោម)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ប្រាសាទចារ (រូបថត៖ រឿន សោម)



ប្រាសាទចារ (រូបថត៖ រឿន សោម)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទចារ មេទ្វារខាងត្បូង (រូបថតៈ រឿន សោម)

អត្ថបទដោយៈ ហ៊ុន ឈុនតេង




សិលាចារឹកប្រាសាទចារ មេទ្វារខាងត្បូង (រូបថត៖ រឿន សោម)




សិលាចារឹកប្រាសាទចារ មេទ្វារខាងត្បូង (រូបថត៖ រឿន សោម)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង